**សលាកប័ត្រព័ត៌មាន ៖** ការកើនឡើងនៃការបង្ក្រាបដោយហិង្សាទៅលើចលនាសហជីព
**ពេលវេលា ៖** ខែធ្នូ ឆ្នាំ២០១៥ ដល់ ខែកុម្ភៈ ឆ្នាំ២០១៦
**ទិដ្ឋភាពរួម ៖** អំពើហិង្សាថ្មីៗក្នុងអំឡុងពេលតវ៉ារបស់អតីតអ្នកបើកបរក្រុមហ៊ុនទេសចរណ៍កាពីតូល បានបង្ហាញនូវការកើនឡើងនៃការបង្ក្រាបរបស់រាជរដ្ឋាភិបាលកម្ពុជា("រដ្ឋាភិបាល") ទៅលើចលនាសហជីព សិទ្ធិការងារ និងលើសេរីភាពខាងជួបប្រជុំ និងខាងសមាគមដែលជាសេរីភាពមូលដ្ឋាន។

## សេចក្ដីផ្ដើម

ប៉ុន្មានខែចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ត្រូវបានមើលឃើញថាមានព្រឹត្តិការណ៍ជាច្រើនដែលចលនាសហជីពត្រូវបានគាបសង្កត់យ៉ាងឃោរឃៅពីសំណាក់អាជ្ញាធរ។ ការបង្ក្រាបដោយហិង្សានាពេលថ្មីៗលើការតវ៉ាដោយអ្នកបើកបរឡានក្រុងដែលជាអតីតបុគ្គលិកក្រុមហ៊ុនកាពីតូល ខូ.អិល.ធី.ឌី ដែលគេស្គាល់ថាកាពីតូលទេសចរណ៍ស្ថិតនៅរាជធានីភ្នំពេញបានបង្ហាញនូវវិធីសាស្ត្ររបស់អាជ្ញាធរកម្ពុជាក្នុងការគាំទ្រឱ្យមានការប្រើអំពើហិង្សាប្រឆាំងនឹងអ្នកតវ៉ាស្របច្បាប់ និងការគាបសង្កត់សហជីពឯករាជ្យ។ ផ្ទុយពីសព្វមួយដងដែលមន្ត្រីនគរបាលមានវត្តមាននៅកន្លែងធ្វើបាតុកម្មដោយសន្តិវិធី និងការឃាំឃីតាមផ្លូវតុលាការទៅលើចលនាសហជីពឯករាជ្យ នគរបាលបរាជ័យក្នុងការធ្វើអន្តរាគមន៍ដើម្បីទប់ស្កាត់ពីការវាយប្រហារដ៏ឃោរឃៅពីសំណាក់ក្រុមអ្នកបើកម៉ូតូទេសចរណ៍ទៅលើអ្នកបើកបររថយន្តដែលតវ៉ានោះ។ ជាងនេះទៅទៀត ខណៈដែលជនរងគ្រោះពីការវាយប្រហារត្រូវបានចាប់ខ្លួន ជនដៃដល់ពិតប្រាកដបែរជាមិនជាប់ទោសទណ្ឌទាល់តែសោះ។ ប៉ុន្តែនេះមិនមែនមានតែមួយករណីនេះទេ ដែលនេះគ្រាន់តែជាហេតុការណ៍មួយក្នុងចំណោមហេតុការណ៍ជាច្រើនដែលសិទ្ធិការងារ និងសេរីភាពមូលដ្ឋានរបស់កម្មករត្រូវបានរំលោភបំពាន។ សលាកប័ត្រនេះនឹងបង្ហាញពីករណីបង្ក្រាបដោយហិង្សានាពេលថ្មីៗលើចលនាសហជីព និងពិចារណាពីភាពជាប់ទាក់ទងទៅនឹងបញ្ហាសិទ្ធិមនុស្ស។

សលាកប័ត្រនេះតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## ការតវ៉ាចំពោះក្រុមហ៊ុនទេសចរណ៍កាពីតូល

មកដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ក្រុមហ៊ុនទេសចរណ៍កាពីតូលបានបណ្តេញអ្នកបើកបរចំនួន ៤៥ នាក់បន្ទាប់ពីអ្នកទាំងនោះគាំទ្រ និងព្យាយាមបង្កើតសហជីព។ ពួកគេមានការបារម្ភទាក់ទងនឹងលក្ខខណ្ឌការងារដែលពិបាកនឹងស៊ូទ្រាំ ទើបពួកគេព្យាយាមបង្កើតសហជីពដើម្បីធ្វើឱ្យលក្ខខណ្ឌការងារទាំងនេះប្រសើរឡើង។ តែទោះជាយ៉ាងណា ការខិតខំប្រឹងប្រែងរបស់ពួកគេបានខកខានបន្ទាប់ពីក្រុមហ៊ុនកាពីតូលទេសចរណ៍ធ្វើការតបតវិញដោយបណ្តេញមន្ត្រីសហជីព និងបុគ្គលិកដែលជាប់ពាក់ព័ន្ធនឹងការបង្កើតសហជីពចេញពីការងារ។ បើទោះបីជាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាកាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ បង្គាប់ឲ្យក្រុមហ៊ុនអនុញ្ញាតឲ្យកម្មករចូលធ្វើការវិញ និងដីការសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញចុះថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០១៥ ឲ្យកម្មករចូលធ្វើការវិញក្នុងរយៈពេល ៤៨ ម៉ោងក៏ដោយ ក៏ភាគីក្រុមហ៊ុនមិនអនុវត្តតាមនីតិវិធីច្បាប់ ហើយបានបន្តយាយីដល់អតីតអ្នកបើកបរទាំងនោះដែលព្យាយាមអនុវត្តសិទ្ធិការងារ និងសេរីភាពមូលដ្ឋានរបស់ខ្លួន។ ការបណ្តេញអតីតអ្នកបើកបររថយន្តទាំងនេះ និងការបង្ក្រាបទៅលើសកម្មជនផ្សេងទៀតបាននាំឱ្យមានការតវ៉ាជាបន្តបន្ទាប់នឹងក្រុមហ៊ុនទេសចរណ៍កាពីតូល។

នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោងប្រមាណជា ៩.៤០ នាទីព្រឹក អ្នកតវ៉ាប្រហែលជា ៥០ នាក់ត្រូវបានក្រុមអ្នកបើកបរម៉ូតូកទេសចរណ៍ដែលគេស្គាល់ថាមានជាប់ពាក់ព័ន្ធយ៉ាងពិតប្រាកដជាមួយនឹងសមាគមរួមគ្នាដើម្បីអភិវឌ្ឍន៍កម្ពុជា ("ស.រ.អ.ក") វាយប្រហារយ៉ាងហិង្សានៅខាងក្រៅទីស្នាក់ការក្រុមហ៊ុនទេសចរណ៍កាពីតូលក្នុងខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។ ស.រ.អ.ក ធ្លាប់មានប្រវត្តិធ្វើបាតុកម្មប្រឆាំងនឹងក្រុមអង្គការសង្គមស៊ីវិល និងអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជាលោក សូរិយ៉ា ស៊ូបេឌី តាមការសំណើរបស់សាលាក្រុង និងឈ្មួញមួយចំនួនជាថ្នូរនឹងកិច្ចសន្យារកស៊ីនានា។ ក្រុមជនដៃដល់មានគ្នាប្រមាណជា ៥០ នាក់ ដែលជាអ្នកបើកបរម៉ូតូកទេសចរណ៍បានវាយប្រហារលើអតីតអ្នកបើកបររថយន្តក្រុងខណៈពេលដែលពួកគេព្យាយាមរាំងរថយន្តទេសចរណ៍របស់ក្រុមហ៊ុនកាពីតូលក្នុងការចេញដំណើរចេញពីទីស្នាក់ការរបស់ខ្លួន។ ការវាយប្រហារដ៏គួរឱ្យរន្ធត់នោះយ៉ាងហោចណាស់មានមនុស្សចំនួន ១៤ នាក់រងរបួស រួមមានទាំងអតីតអ្នកបើករថយន្តក្រុងដែលកំពុងធ្វើការតវ៉ា អ្នកឃ្លាំមើលសិទ្ធិមនុស្សម្នាក់ និងមន្ត្រីនគរបាលម្នាក់ដែលរូបភាពទាំងនេះត្រូវបានអ្នកឃ្លាំមើលសិទ្ធិមនុស្សថតបានជាវីដេអូដែលបង្ហាញថាអ្នកបើកបរម៉ូតូកទេសចរណ៍កំពុងវាយដំនឹងដំបង របាំងដែក ញញួរ និងស្នាប់ដៃទៅលើអ្នកតវ៉ានឹងដំបង របាំងដែកញញួរ និងស្នាប់ដៃ។[1] ក្នុងអំឡុងពេលមានការវាយដំដ៏ឃោឃៅនោះ នគរបាលមិនបានអន្តរាគមន៍ ហើយមានការលើកឡើងថានគរបាលមួយចំនួនបានចូលរួមក្នុងអំពើហិង្សានោះទៀតផង។[2] អ្នកបង្កអំពើហិង្សាទាំងនោះមិនត្រូវបានចាប់

[1] លីកាដូ អ្នកបើកបររថយន្តកាពីតូលត្រូវបានមនុស្សស្លៀកពាក់ស៊ីវិលវាយដំ យូធូប (ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦) សូមចូលទៅកាន់តំណ៖ http://bit.ly/1Q2mv2j ដើម្បីទស្សនាវីដេអូឃ្លីប។

[2] លីកាដូ "សង្គមស៊ីវិលថ្កោលទោសយ៉ាងធ្ងន់ធ្ងរចំពោះអំពើហិង្សាទៅលើអតីតអ្នកបើកបររថយន្តកាពីតូល" (ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៦) http://bit.ly/1LukE0P

ខ្លួនឡើយ ចំណែកឯជនរងគ្រោះចំនួនពីរនាក់ត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលតវ៉ានោះរួមមានអ្នកបើកបររថយន្តក្រុងលោក ណាន វណ្ណា និងលោក រស់ ស៊ីផៃ។ ពីរថ្ងៃក្រោយមក គឺនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៦ ពួកគេត្រូវបានសាលាដំបូងរាជធានីភ្នំពេញចោទប្រកាន់ពីបទហិង្សាដោយចេតនា រារាំងអគ្គាធរសាធារណៈនិងរារាំងចរាចរណ៍ ហើយពួកគេត្រូវបានបន្តឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារព្រៃស។[3] នៅថ្ងៃដដែលនោះ ថ្នាក់ដឹកនាំសហជីពឯករាជ្យចំនួនបួននាក់ដែលធ្វើការលើកស្ទួយសិទ្ធិការងារគឺ លោក អាត់ ធន់ ប្រធានសហភាពការងារកម្ពុជា លោក គង់ អាទិត្យ អគ្គលេខាធិការសហភាពការងារកម្ពុជា លោក សុខ ឈុនអឿង ប្រធានសមាគមកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា និងលោក អៀន គឹមហ៊ុន លេខាធិការសហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា ត្រូវរងការចោទប្រកាន់ចំនួនបីបទល្មើសនេះផងដែរ។[4] គ្មាននរណាម្នាក់ក្នុងចំណោមអ្នកដឹកនាំទាំងបួនមានវត្តមាននៅកន្លែងកើតហេតុនោះទេ ដូច្នេះការចោទប្រកាន់នេះបង្ហាញពីការកំណត់មុខសញ្ញាបង្ក្រាបលើចលនារបស់សហជីព។ ការវិវឌ្ឍនេះគឺគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើសកម្មភាពសហជីពឯករាជ្យគ្រប់ទម្រង់ ហើយជាពិសេសទៅទៀតនោះគឺមានការឃាយីតាមរយៈមាត្រា ២៩ នៃសេចក្តីស្នើច្បាប់ស្តីពីសហជីពដែលផ្តល់ឆន្ទានុសិទ្ធិដល់តុលាការការងារក្នុងការរំលាយសហជីពមួយ ដោយសំអាងលើហេតុផលមិនច្បាស់លាស់ជាច្រើនរួមទាំង "ការប្រព្រឹត្តមិនត្រឹមត្រូវ" របស់ថ្នាក់ដឹកនាំណាម្នាក់។ ការឃាយីផ្នែកប្រព័ន្ធតុលាការមកលើថ្នាក់ដឹកនាំសហជីពចំនួនបួនរូប ដែលមិនបានជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការតវ៉ាជាក់ស្តែង និងជនរងគ្រោះទាំងពីរនៃអំពើហិង្សានេះ បង្ហាញឲ្យឃើញនូវការប្តេជ្ញារបស់រដ្ឋាភិបាលដើម្បីបំផ្លាញសហជីពឯករាជ្យ។

ស្របពេលជាមួយគ្នានេះដែរ ពុំមានកិច្ចខិតខំប្រឹងប្រែងពិតប្រាកដណាមួយត្រូវបានធ្វើឡើងដើម្បីនាំខ្លួនជនដៃដល់ក្នុងអំពើហិង្សាយកមកផ្តន្ទាទោសឡើយ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺលោក ឯ សុភស្ស ប្រធាន ស.រ.អ.ក បានបង្ហាញពីចេតនារបស់ខ្លួនក្នុងការប្តឹងថ្នាក់ដឹកនាំសហជីព និងអង្គការសង្គមស៊ីវិលដែលបង្កឱ្យមានអំពើហិង្សា បើទោះបីជាមានភស្តុតាងបង្ហាញថាសមាជិករបស់ ស.រ.អ.ក ខ្លួនឯងជាអ្នកផ្តើមឲ្យមានការវាយដំនោះក៏ដោយ។[5] ហេតុការណ៍នេះបានស្តែងចេញនូវបញ្ហារំខានមួយចំនួនដូចជា ការរំលោភបំពានលើសិទ្ធិការងារដែលក្រុមហ៊ុនបានបញ្ឈប់បុគ្គលិកពីការងារដែលគ្រាន់តែធ្វើការចងក្រងសហជីពដោយគ្មានទោសទណ្ឌ ការមិនអនុវត្តតាមនូវសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងសេចក្តីសម្រេចរបស់សាលាដំបូង

[3] នីម ឆេង " អតីតអ្នកបើកបររថយន្តក្រុងកាពីតូលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើវាយតប់គ្នា" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៦) http://goo.gl/RCEqJr

[4] សេក ឧត្តម និង ថៃលីវ អូខូននែល "ប្រធានសហជីពរិះគន់ការចោទប្រកាន់ជុំវិញការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនទេចរណ៍កាពីតូល" សារព័ត៌មាន*ខេមបូឌា ដេលី* (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦) http://bit.ly/1KXtoS1

[5] ឡាយ សាមាន "អ្នករងការចោទប្រកាន់ថាជាអ្នកវាយដំក្នុងការតវ៉ានៅហ៊ុនកាពីតូលថានឹងប្តឹង *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០១៦) http://goo.gl/QTrmHx

រាជធានីភ្នំពេញ ការដែលរដ្ឋាភិបាលទទួលយកវិធីសាស្ត្រនៃការប្រើអំពើហិង្សាប្រឆាំងនឹងអ្នកតវ៉ាដោយសន្តិវិធី និងការឃាយឃីតាមប្រព័ន្ធតុលាការប្រឆាំងនឹងអ្នកដឹកនាំ និងសមាជិកក្រុមអ្នកធ្វើការខាងសិទ្ធិការងារ។

## ការកើនឡើងនៃការបង្ក្រាបលើចលនាសហជីពនាពេលថ្មីៗនេះ

ការវាយដំលើអតីតអ្នកបើកបររថយន្តក្រុមហ៊ុនទេសចរណ៍កាពីតូលគឺជាហេតុការណ៍ចុងក្រោយបំផុតក្នុងចំណោមហេតុការណ៍ថ្មីៗប្រហាក់ប្រហែលគ្នាដែលសហជីពរងការគាបសង្កត់។ កម្មករតែងជាកម្មវត្ថុនៃអំពើហិង្សាផ្នែករូបរាងកាយ ការយាយីតាមប្រព័ន្ធតុលាការ និងការបណ្តេញចេញពីការងារដោយសារព្យាយាមអនុវត្តសេរីភាពមូលដ្ឋានរបស់គេ ឬសិទ្ធិការងារដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ ក្រុមកម្មករដែលធ្វើការនៅរបស់រោងចក្រស្តាឡៃអាគៀរ៉ែល ស្ថិតក្នុងខេត្តកណ្តាលប្រមាណ ៦០០ នាក់ត្រូវបានវាយដំយ៉ាងដំណំពីសំណាក់សន្តិសុខប្រមាណ ១០ នាក់ និងជនពាលប្រមាណ ៣០ នាក់ប្រដាប់ដោយបំពង់ទីប និងកាំបិតតាំងតោ ដោយបន្សល់ទុកនូវកម្មករ ៨នាក់រងរបួស។ ហេតុការណ៍នេះបានកើតឡើងខណៈពេលដែលក្រុមកម្មករព្យាយាមធ្វើដំណើរទៅរាជធានីភ្នំពេញដើម្បីតវ៉ាប្រឆាំងនឹងការសម្រេចដ៏ចម្រូងចម្រាស់របស់រោងចក្រ ស្តាឡៃ អាគៀរ៉ែល កាលពីខែមករាដែលបញ្ឈប់លោក ទ្រី សេត្រា តំណាងសហជីពសាមគ្គីភាពការងារកម្ពុជា។ កម្មករទាំងនោះធ្វើការតវ៉ាប្រឆាំងនឹងលក្ខខណ្ឌការងាររបស់ពួកគេ និងការបណ្តេញចេញលោក ទ្រី សេត្រា ហើយក្រោយមកមានកម្មករប្រាំពីរនាក់ផ្សេងទៀតត្រូវបានបញ្ឈប់ពីការងារដោយចោទថាពួកគេញុះញង់ឱ្យកម្មករធ្វើកូដកម្ម។[6] មួយផ្នែកនៃការតវ៉ានេះ សហជីពសាមគ្គីភាពការងារកម្ពុជាបានដាក់ចេញនូវលក្ខខណ្ឌជាក់លាក់ ១៨ ចំនុចដើម្បីកែលម្អលក្ខខណ្ឌការងារឱ្យបានប្រសើរឡើង ហើយលក្ខខណ្ឌ ១៥ ចំនុចក្នុងចំណោមលក្ខខណ្ឌទាំងនោះត្រូវបានឯកភាពគ្នានៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៦ បន្ទាប់ពីមានការចូលរួមចរចារដោយលោកអភិបាលស្រុក។ កម្មករសង្ឃឹមថាលក្ខខណ្ឌបីចំនុចដែលនៅសេសសល់មានដូចជា ការទទួលលោក ទ្រី សេត្រា ឱ្យចូលធ្វើការវិញ ការទូទាត់ប្រាក់ខែពេញដល់កម្មករដែលចូលរួមក្នុងការតវ៉ា និងកែលម្អលក្ខខណ្ឌការងារទូទៅនឹងត្រូវឯកភាពនៅក្នុងកិច្ចចរចារបន្ទាប់។ ប្រធានសហជីពសាមគ្គីភាពការងារកម្ពុជាបានបញ្ជាក់ថាសហជីពសាមគ្គីភាពការងារកម្ពុជា និងខាងភាគីរោងចក្រគ្រោងនឹងនាំយកបញ្ហានេះដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីធ្វើការដោះស្រាយ។

ចាប់តាំងពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ កម្មកររោងចក្រនៅខេត្តកំពង់ស្ពឺបានផ្ទុះការតវ៉ាបន្តបន្ទាប់ប្រឆាំងនឹងលក្ខខណ្ឌការងារនៅក្នុងរោងចក្រ អ៊ែជ្យាយ៍ ស្វេតធឺ។ បន្ទាប់មកនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ កម្មករនយោជិតបានមកសុំកិច្ចអន្តរាគមន៍ពីសម្ព័ន្ធសហជីពចលនាកម្មករ។ នៅក្នុងអំឡុងពេលនៃកិច្ចសម្របសម្រួលរបស់សម្ព័ន្ធសហជីពចលនាកម្មករ ភាគីខាងរោងចក្របានប្រើប្រាស់ដីការក្សាការពាររបស់សាលាដំបូងខេត្តកំពង់ស្ពឺនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៦ ដោយបង្គាប់ឱ្យកូដករចូលធ្វើការវិញក្នុងរយៈពេល ៤៨ ម៉ោងដើម្បីឆ្លើយតបទៅនឹងការទាមទារ តែផ្ទុយទៅវិញការឱ្យចូលធ្វើការនោះគឺមិនមានជាដំណោះស្រាយសមស្របណា

[6] អូន ភាព សហជីពនយាយាថាសន្តិសុខកាប់កម្មករនឹងកំបិតហាន់សាច់ *ខេមបូឌា ដេលី* (ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦) http://goo.gl/RCEqJr

មួយនៅឡើយ ខណៈពេលដែលការទាមទាររបស់សម្ព័ន្ធសហជីពចលនាកម្មករ ត្រូវបានច្រានចោលជាបន្តបន្ទាប់។

នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ការតវ៉ាបានឈានចូលដល់អំពើហិង្សាដោយសារមានការប៉ះទង្គិចគ្នានៅខាងក្រៅរោងចក្ររវាងកម្មករនិងក្រុមជនពាលដែលដឹកនាំដោយសហព័ន្ធសហជីពសេរីពលករខ្មែរ គឺមានលោក សុខ រ៉ាវុធ ដែលមានទំនាក់ទំនងជាមួយនឹងរោងចក្រ អ៊ែជ្យាយ៍ ស្វេតចឺ។ បុគ្គលដែលមានទំនាក់ទំនងជាមួយ សហព័ន្ធសហជីពសេរីពលករខ្មែរ ត្រូវបានគេរាយការណ៍ថាបានវាយដំ នឹងដំបង និងបំពង់ទីបដែកទៅលើក្រុមអ្នកតវ៉ា ខណៈដែលតំណាងរបស់សម្ព័ន្ធសហជីពចលនាកម្មករ បានមកដល់មុខរោងចក្រ នៅក្នុងហេតុការណ៍នេះតំណាងសម្ព័ន្ធសហជីពចលនាកម្មករចំនួន ៥ នាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅសាលាដំបូងខេត្តកំពង់ស្ពឺនិងត្រូវបានចោទពីបទ ហិង្សាដោយចេតនា ញុះញង់ឱ្យប្រព្រឹត្តបទល្មើស និងមិនគោរពតាមដីការរបស់តុលាការបញ្ចប់ការតវ៉ា។ សមាជិកសហជីពទាំងប្រាំនាក់ដែលត្រូវបានចាប់ខ្លួននោះរួមមានលោក ខាត់ ឡូត អនុប្រធាន សម្ព័ន្ធសហជីពចលនាកម្មករ និងសមាជិករួមមានលោក ចាម សំណាង លោកព្រំ ប៊ុនថន លោក ម៉ៅ ម៉ុយ និងលោក អាន ថុនា ទៅចូលរួមសម្របសម្រួលនៅខេត្តកំពង់ស្ពឺដើម្បីស្វែងរកដំណោះស្រាយជូនកម្មករ ។ បន្ទាប់ពីមានបាតុកម្មទ្រង់ទ្រាយធំនៅខាងក្រៅសាលាខេត្តកំពង់ស្ពឺនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ និងការអំពាវនាវពីប្រធាន សម្ព័ន្ធសហជីពចលនាកម្មករ ឱ្យដោះលែងតំណាងទាំងប្រាំនាក់ និងនាំយកជនដៃដល់នៃអំពើហង្សាទៅផ្តន្ទាទោសរួចមក តំណាងទាំងប្រាំនាក់ក៏ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦។ ហើយបន្ទាប់មកលោក ប៉ាវ ស៊ីណា ជាប្រធានសម្ព័នសហជីពចលនាកម្មករ និងសហការីមួយរូបទៀតគឺលោក ស៊ុត ចិត្រ ត្រូវបានសាលាដំបូងខេត្តកំពង់ស្ពឺធ្វើការចោទប្រកាន់ដូចគ្នាទៅនឹងមន្ត្រីទាំង ៥ រូបខាងលើដែរ បើទោះបីជាមិនមានការឃុំខ្លួន តែរូបលោកទាំងពីរត្រូវបានដាក់នៅក្រោមការត្រួតរបស់តុលាការខេត្តកំពង់ស្ពឺ។

ដូចដែលបានលើកឡើងខាងដើមពីករណីក្រុមហ៊ុនទេសចរណ៍កាពីតូល យើងអាចកត់សម្គាល់បានថាហិង្សាលើអ្នកតវ៉ានៅខេត្តកំពង់ស្ពឺត្រូវបានរៀបចំឡើងដោយក្រុមមនុស្សដែលមានសម្ព័ន្ធភាពជាមួយនឹងថ្នាក់ដឹកនាំនៅរោងចក្រ អេជ្យាល ស្វីតជឺ ជាជាងក្រុមហ៊ុន ឬក៏អាជ្ញាធរ។ យ៉ាងណាក៏ដោយ អជ្ញាធរហាក់ដូចជាគាំទ្រដោយស្ងៀមស្ងាត់ចំពោះអំពើហិង្សានេះ ព្រោះពួកគេខកខានក្នុងការចាត់វិធានការសមស្របណាមួយដើម្បីបញ្ឈប់អំពើហិង្សា ឬធ្វើការស៊ើបអង្កេតឱ្យមានប្រសិទ្ធិភាពដើម្បីនាំយកជនដៃដល់ទៅផ្តន្ទាទោស។ ជាងនេះទៅទៀត មន្ត្រីមួយចំនួនរបស់សម្ព័ន្ធសហជីពចលនាកម្មករ ត្រូវបានចាប់ខ្លួននិងបទចោទចំពោះទង្វើរបស់ពួកគេដែលគ្រាន់តែរៀបចំការតវ៉ាស្របច្បាប់ ហើយទង្វើដូចគ្នាបានកើតឡើងចំពោះករណីក្រុមហ៊ុនទេសចរណ៍កាពីតូលផងដែរ។ របត់បែបនេះគឺជាការរំខានយ៉ាងខ្លាំងដោយសារក្រុមហ៊ុនកំពុងតែរីករាយនឹងសេរីភាពក្នុងការគាបសង្កត់តាមអំពើចិត្ត និងបំភិតបំភ័យកម្មករពីការចូលរួមស្របច្បាប់ក្នុងសកម្មភាពសហជីពតាមរយៈការប្រើប្រាស់ក្រុមជនអន្ធពាល។

កាលពីខែធ្នូ ឆ្នាំ២០១៥ នៅក្រុងបាវិត ខេត្តស្វាយរៀងមានអំពើហិង្សាផ្ទុះឡើងដោយសារតែការគាបសង្កត់របស់អាជ្ញាធរទៅលើការតវ៉ារបស់កម្មករនៅតំបន់សេដ្ឋកិច្ចពិសេសមហាថាន និងថៃសេង។ ការតវ៉ាបានចាប់ផ្តើមនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ដោយសារតែកម្មករប្រតិកម្មទៅនឹងការបដិសេធរបស់រដ្ឋាភិបាលក្នុងការដំឡើងប្រាក់ឈ្នួលអប្បរមា ១៤៨ ដុល្លារក្នុងមួយខែតាមការទាមទារ។ ការតវ៉ាបានកើនឡើងរាល់ថ្ងៃដោយកម្មករច្រើនឡើងៗបានចូលរួមក្នុងការទាមទារនេះ ជាហេតុបង្ខំឱ្យមានការបិតតំបន់សេដ្ឋកិច្ចពិសេសទាំងពីរនៅថ្ងៃទី១៧ និង ១៨ ខែធ្នូ ឆ្នាំ២០១៥ បណ្តាលឱ្យប៉ះពាល់កម្មករប្រហែល ៣០.០០០ នាក់។ អំពើហិង្សាបានផ្ទុះឡើងបណ្តាលឱ្យតំបន់ទាំងមូលស្ថិតក្នុងភាពចលាចល ហើយកងកម្លាំងយោធាប្រមាណជាង ៦០០ នាក់ត្រូវបានដាក់ពង្រាយដើម្បីបង្ក្រាបភាពវឹកវរនេះ។[7] នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ សមត្ថកិច្ចបានបំបែកក្រុមអ្នកតវ៉ាប្រមាណ ៨.០០០ នាក់យ៉ាងហិង្សាដោយប្រើរថយន្តបាញ់ទឹក និងបានចាប់ខ្លួនកម្មករចំនួន ៥៨ នាក់ ប៉ុន្តែត្រូវដោះលែងវិញនៅល្ងាចថ្ងៃដដែលក្រោយពីអ្នកទាំងនោះយល់ព្រមថាមិនចូលរួមក្នុងការតវ៉ាផ្សេងទៀត។ បន្ទាប់ពីហេតុការណ៍នេះកើតឡើង តំណាងប្រចាំខេត្តស្វាយរៀងរបស់សម្ព័ន្ធសហជីពចលនាកម្មករ លោក ជា ឧត្តម បានពន្យល់ថា *"ប៉ូលីសបានព្យាយាមប្រានពួកគេ ហើយពួកគេខឹងនឹងប៉ូលីស ដូច្នេះកម្មករគប់ដបទឹកសុទ្ធ និងទឹកកកទៅលើប៉ូលីស ហើយប៉ូលីសប្រើទុយោបាញ់ទឹកបំបែកពួកគេតែម្តង"*។ [8] យ៉ាងហោចណាស់មានកម្មករ និងអ្នកបើករថយន្តដឹកកម្មករ ១១ នាក់ ត្រូវបានចាប់ខ្លួន និងចោទពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ហិង្សាដោយចេតនា និង ញុះញង់ ដោយសារទង្វើរបស់ពួកគេទាក់ទងនឹងការតវ៉ានេះ។[9] ក្រៅពីនេះក៏មានសេចក្តីប្រកាសផងដែរថា រោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសបានសម្រេចផ្តល់ប្រាក់ឈ្នួលឱ្យកម្មករពាក់កណ្តាលប៉ុណ្ណោះសម្រាប់រយៈពីរថ្ងៃនៃការតវ៉ាដែលបណ្តាលឱ្យតំបន់សេដ្ឋកិច្ចទាំងមូលបិទទាំងស្រុងនៅថ្ងៃទី១៧ និង ១៨ ខែធ្នូ ឆ្នាំ២០១៥។[10]

ការរើសអើងប្រឆាំងនឹងសមាជិកសហជីពនៅក្នុងក្រុងបាវិត គឺរីករាលដាលជាក់ស្តែងដោយសារមានតែរោងចក្រចំនួន ៥ ប៉ុណ្ណោះក្នុងចំណោមរោងចក្រប្រមាណជា ៤៥ នៅតំបន់នោះដែលព្រមទទួលសមាជិកសហជីពឱ្យធ្វើការ។ ភាពគ្មានម្ចាស់ការក្នុងអំឡុងពេលតវ៉ាថ្មីៗនេះគឺភាគច្រើនដោយសារតែកម្សោយរបស់សហជីពនៅក្នុងតំបន់នោះ និងផលលំបាកក្នុងការចរចាដើម្បីផលប្រយោជន៍រួមរបស់កម្មករឱ្យមានស្ថេរភាព និងលក្ខខណ្ឌការងារជាមួយថៅកែរោងចក្រ។ ពុំមានសហជីពសំខាន់ណាមួយនៅពីក្រោយការតវ៉ានេះឡើយ ហើយកង្វះខាតការរៀបចំជាលក្ខណៈប្រព័ន្ធក្នុងការតស៊ូមតិនេះហើយទើបធ្វើឲ្យកម្មកររឹតតែខកចិត្តខ្លាំងឡើង ដែលងាយឈានទៅប្រើអំពើហិង្សាភ្លាមៗ។ ភាពវឹកវរនៃការតវ៉ាដោយមិនមានការដឹកនាំច្បាស់លាស់ធ្វើឱ្យពិបាក

---

[7] សមត្ថកិច្ច និងអ្នកតវ៉ាប៉ះទង្គិចគ្នានីក្រុងបាវិត, *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥) <http://www.phnompenhpost.com/national/cops-protesters-clash-bavet>

[8]ដដែល

[9] កង សុជា ៖ ស្ត្រី ១១ នាក់ត្រូវបានចាប់ខ្លួនជុំវិញអំពើកុប្បកម្មនៅតំបន់សេដ្ឋកិច្ចពិសេសក្រុងបាវិត, *ខេមបូឌា ដេលី* (ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥) https://goo.gl/rpFl10

[10] កង សុជា ៖ រោងចក្រកាត់ប្រាក់ឈ្នួលបន្ទាប់ពីការតវ៉ានៅតំបន់សេដ្ឋកិច្ចពិសេសក្រុងបាវិត, *ខេមបូឌា ដេលី* (ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ ២០១៥)<https://www.cambodiadaily.com/news/factories-to-withhold-wages-after-bavet-city-sez-protests-104084/>

យ៉ាងខ្លាំងក្នុងការបង្ហាញឱ្យឃើញពីការរួបរួមគ្នា ដែលបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរធ្វើការបំបែកការតវ៉ា និងប្រានចោលការព្រួយបារម្ភរបស់កម្មករ ឬថាជាកុប្បកម្មទៅវិញ។ ការវិភាគនេះគឺគាំទ្រដោយនាយកប្រចាំប្រទេសនៃមជ្ឈមណ្ឌលសាមគ្គីភាពដែលមានប្រសាសន៍ពាក់ព័ន្ធនឹងស្ថានការណ៍នៅក្រុងបាវិតនេះថា *"ប្រសិនបើនៅទីនោះមានសហជីពដែលអាចមានសិទ្ធិចរចាជាសមូហភាព នោះវាពិតជាអាចទប់ស្កាត់ស្ថានការណ៍បែបនេះមិនឱ្យកើតឡើងឡើយ"*។[11]

## សេចក្តីស្នើច្បាប់សហជីព

ផ្ទុយទៅនឹងព្រឹត្តិការណ៍នៃការបង្ក្រាបលើចលនាសហជីពកាន់មានការកើនឡើង រដ្ឋាភិបាលហាក់ប្តេជ្ញាដាក់ចេញនូវសេចក្តីព្រាងច្បាប់សហជីពថ្មីដែលផ្តល់អំណាចដល់រដ្ឋាភិបាលយ៉ាងច្រើនដើម្បីគ្រប់គ្រង និងរឹតបន្តឹងប្រតិបត្តិការរបស់សហជីព និងគំរាមកំហែងដល់ជីវភាពរបស់សហជីពទាំងនោះ។ រដ្ឋាភិបាលមិនបានផ្សព្វផ្សាយនូវសេចក្តីព្រាងច្បាប់ដែលមានការកែប្រែច្រើនដងរួចទៅហើយ ដែលច្បាប់នេះប៉ះពាល់យ៉ាងខ្លាំងទៅលើសិទ្ធិការងារដោយសារមិនមានតម្លាភាពជុំវិញការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់នេះ។ សេចក្តីព្រាងច្បាប់ដែលបែកធ្លាយចុងក្រោយគឺមានការគំរាមកំហែងធ្ងន់ធ្ងរលើសិទ្ធិការងារ ព្រមទាំងសេរីភាពខាងសមាគម ជួបប្រជុំ និងបញ្ចេញមតិ ហើយត្រូវបានសហជីព និងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិធ្វើការថ្កោលទោសយ៉ាងខ្លាំង។[12] ច្បាប់នេះបានការគំរាមកំហែងដល់ការការចុះបញ្ជីដែលមានបែបបទស្មុគស្មាញ (មាត្រា ១៤) និងតម្រូវឲ្យមានរបាយការណ៍ (មាត្រា ១៧) ឆន្ទានុសិទ្ធិរបស់តុលាការការងារក្នុងការរំលាយសហជីពដោយយោងលើហេតុផលមិនច្បាស់លាស់ដូចជា *"ការប្រព្រឹត្តិមិនត្រឹមត្រូវ"* របស់ថ្នាក់ដឹកនាំសហជីពណាម្នាក់ (មាត្រា ២៩) និងហាមប្រាមសកម្មភាពសហជីពដោយគ្មានមូលដ្ឋានច្បាស់លាស់ ដូចជាសកម្មភាព *"ផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈ"* ឬដែល *"បង្កបញ្ហាដោយសារតែកម្មវត្ថុនោះបម្រើដល់និន្នាការនយោបាយ"* (មាត្រា ៦៥)។ ប្រសិនបើច្បាប់សហជីពត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្នជាមួយនឹងបទបញ្ញត្តិដែលមានលក្ខណៈរឹតបន្តឹងដ៏គួរឱ្យព្រួយបារម្ភបែបនេះ ច្បាប់នេះហាក់បន្តបង្ក្រាបទៅលើសិទ្ធិការងារនៅក្នុងប្រទេសកម្ពុជាដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ ។

## សិទ្ធិការងារ និងសេរីភាពខាងសមាគម និងជួបប្រជុំ

សិទ្ធិការងារ និងសេរីភាពមូលដ្ឋានខាងសមាគម និងជួបប្រជុំត្រូវបានការពារនៅក្រោមច្បាប់ជាតិ និងអន្តរជាតិ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ប.ស.ម") និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដែលច្បាប់ទាំងពីរមានអនុភាពនៅក្នុងច្បាប់កម្ពុជាដូចដែល

[11] កង សុជា ៖ តំបន់សេដ្ឋកិច្ចពិសេសក្រុងបាវិតបិតទ្វារពេលមានការតវ៉ា *ខេមបូឌា ដេលី* (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥) <https://www.cambodiadaily.com/news/bavet-city-sezs-close-amid-violent-protests-103351/>

[12] អង្គការឃ្លាំមើលសិទ្ធិមនុស្សអំពាវនាវឱ្យធ្វើវិសោធនកម្មសេចក្តីព្រាងច្បាប់សហជីពដើម្បីការពារសិទ្ធិកម្មករ, ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ https://www.hrw.org/news/2015/12/17/cambodia-revise-union-law-protect-worker-rights

បានបញ្ជាក់ដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅឆ្នាំ២០០៧។[13] សិទ្ធិដែលបានលើកឡើងខាងលើត្រូវបានការពារដោយច្បាប់កម្ពុជាដែលទទួលស្គាល់ដោយ ក.អ.ស.ព.ន និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ("ក.អ.ស.ស.វ")។ សិទ្ធិសេរីភាពខាងសមាគមត្រូវបានការពារដោយមាត្រា ២២ នៃ ក.អ.ស.ព.ន និងមាត្រា ៨ នៃ ក.អ.ស.ស.វ ដែលគ្របដណ្ដប់លើសិទ្ធិ *"បង្កើតសហជីព និងចូលរួមសហជីពតាមការជ្រើសរើសរបស់ខ្លួន"* និង *"សិទ្ធិរបស់សហជីពក្នុងការធ្វើសកម្មភាពដោយសេរី"*។ ជាងនេះទៅទៀត មានបទបញ្ញត្តិជាច្រើននៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីសហជីពដែលអាចនឹងរំលោភទៅលើបទដ្ឋាន និងគោលការណ៍នានារបស់អង្គការពលកម្មអន្តរជាតិ ជាពិសេសអនុសញ្ញាលេខ ៨៧ និង ៩៨ របស់ អង្គការពលកម្មអន្តរជាតិ ទាក់ទងទៅនឹងសេរីភាពខាងសមាគម និងសិទ្ធិចរចាជាសមូហភាព។

## សន្និដ្ឋាន

អំពើហិង្សាថ្មីៗពាក់ព័ន្ធនឹងអតីតអ្នកបើកបររថយន្តកាពីតូល និងអំពើហិង្សាព្រមទាំងព្រឹត្តិការណ៍ដ៏តក់ស្លុតផ្សេងៗទៀតដែលរៀបរាប់ក្នុងសលាកប័ត្រនេះគឺជាការក្រើនរំលឹកថា មានការបន្តកើតឡើងនូវការរំលោភបំពានលើសិទ្ធិការងារ និងសេរីភាពមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ ការប្ដេជ្ញារបស់រដ្ឋាភិបាលក្នុងការបង្ក្រាបសកម្មនិយមដែលខ្លួនចាត់ទុកថាជាការគំរាមកំហែងដល់រដ្ឋអំណាចរបស់ខ្លួនមុនការបោះឆ្នោតឆ្នាំ២០១៧ និង ២០១៨ បង្កឲ្យមានការបង្ក្រាបជាលក្ខណៈប្រព័ន្ធគ្រប់ទម្រង់នៃសកម្មភាពសហជីព។ ការប្រើហិង្សាដោយគ្មានប្រណីទៅលើអ្នកតវ៉ាដែលហ៊ានអនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេក្នុងការតវ៉ាដោយសន្តិវិធី ការយាយីតាមប្រព័ន្ធតុលាការលើអ្នកតវ៉ា និងគម្រោងដាក់ចេញនូវច្បាប់សហជីពដែលមានលក្ខណៈគាបសង្កត់ បានរួមចំណែកបង្កើតបរិយាកាសដ៏អាប់អួរមួយដែលកម្មករមានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងសកម្មភាពសហជីព និងអនុវត្តសិទ្ធិរបស់ពួកគេដើម្បីបង្ហាញនូវភាពមិនពេញចិត្តនឹងលក្ខខណ្ឌការងារ។ ការវិវឌ្ឍទាំងនេះគឺជាសូចនករបង្ហាញពីចេតនារបស់រដ្ឋាភិបាលក្នុងការបង្ក្រាបចលនាសិទ្ធិការងារទាំងស្រុង។

ម.ស.ម.ក ជម្រុញឱ្យរដ្ឋាភិបាលចាត់វិធានការដើម្បីធានាថាក្រុមហ៊ុនទាំងអស់ទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះការរំលោភបំពានលើសិទ្ធិការងារ និងសេរីភាពមូលដ្ឋានលើបុគ្គលិកខ្លួន និងធានាថាសិទ្ធិរបស់ជនរងគ្រោះនៃអំពើហិង្សាត្រូវបានគោរពស្របតាមគោលការណ៍នីតិរដ្ឋ។ បន្ថែមពីនេះទៅទៀត ម.ស.ម.ក ជម្រុញឱ្យសាលាដំបូងរាជធានីភ្នំពេញចាត់វិធានការដូចខាងក្រោម ៖

១. ធ្វើការស៊ើបអង្កេតឱ្យមានប្រសិទ្ធិភាពទៅលើបណ្ដឹងនៃអំហិង្សាប្រឆាំងអ្នកតវ៉ា
២. ផ្ដន្ទាទោសជនដៃដល់ក្នុងអំពើហិង្សា និងក្រុមហ៊ុនឲ្យទទួលខុសត្រូវចំពោះអំពើហិង្សា

[13] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, សេចក្ដីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

៣. បទចោទប្រឆាំងនឹងអ្នកតវ៉ា និងថ្នាក់ដឹកនាំសហជីពគួរតែទម្លាក់ចោលទាំងស្រុង រួមទាំងបទចោទប្រឆាំងលើមនុស្សប្រាំមួយនាក់ដែលជាប់ពាក់ព័ន្ធទៅនឹងករណីក្រុមហ៊ុនទេសចរណ៍កាពីតូលផងដែរ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទាក់អ្នកស្រី ឆាយ ឈុនលី អ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក តាមរយៈទូរសព្ទលេខ ៖ +៨៥៥ (០) ១៧ ៥២៨ ០២១ ឬអ៊ីម៉ែល chhunly.chhay@cchrcambodia.org ឬទីប្រឹក្សាច្បាប់ លោក ផាត ដឺប្រ៊ូន ទូរសព្ទលេខ +៨៥៥ (០) ៨៩ ៥៣៦ ២១៥ ឬអ៊ីម៉ែល pat.debrun@cchrcambodia.org**